00602076

F7

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 14 / 09 / 2010
ម៉ោង (Time/Heure): 08:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារថតចម្លង
COPY/COPIE
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2010, 08:59
CMS/CFO: Sann Rada

**ជូនអង្គជំនុំជម្រះតុលាការកំពូល**

ឯកឧត្តម គង់ ស្រ៊ឹម ប្រធានអង្គជំនុំជម្រះតុលាការកំពូល

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **ស៊ិន រិទ្ធ**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **A. KLONOWIECKA-MILART**

ចៅក្រម **Chadra.Nihal Jayasinghe**

Richard J. Rogers
**ប្រធានអង្គភាពគាំពារការការពារក្តី**
ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

**កម្មវត្ថុ: សំណើរបស់អង្គភាព DSS សុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី *(amicus curiae)* នៅអង្គជំនុំជម្រះតុលាការកំពូល**

លោកចៅក្រមជាទីគោរព,

1. លោក កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ ភាគីបានជូនដំណឹងពីគោលបំណងរបស់ពួកគេក្នុងការប្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមទៅអង្គជំនុំជម្រះតុលាការកំពូល ។ អនុលោមទៅតាមវិធាន៣៣ នៃវិធានផ្ទៃក្នុង អង្គភាពគាំពារការការពារក្តី ("DSS") សូមអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ជាផ្នែកនៃបណ្តឹងសារទុក្ខនេះ ។

**សាវតារ**

F7

2. សហព្រះរាជអាជ្ញានៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ បានដាក់សេចក្តីជូនដំណឹងរបស់ពួកគេអំពីបណ្តឹងសារទុក្ខ[1] ។ សេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាមានមូលហេតុនៃបណ្តឹងសារទុក្ខចំនួនបី ដែលលើកឡើងពីបញ្ហាបច្ចេកទេសដ៏សាំញ៉ាំនៃច្បាប់អន្តរជាតិ ។

3. សហមេធាវីរបស់ ឌុច នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ បានដាក់សេចក្តីជូនដំណឹងរបស់ពួកគេអំពីបណ្តឹងសារទុក្ខ ("សេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តី")[2]។ មានការលេចឮពីសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តីថា សហមេធាវីមានបំណងកម្រិតសារណាតម្រិតបញ្ហាយុត្តាធិការ និងប្រមូលផ្តុំទឡ្ហីករណ៍របស់ពួកគេទៅលើបញ្ហាច្បាប់ជាតិ ដូច្នេះបញ្ហាជាច្រើនដែលជាប់ទាក់ ទិននឹងច្បាប់អន្តរជាតិ រួមទាំងបញ្ហាដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ទំនងជាមិនត្រូវបានលើកឡើងឱ្យបានក្បោះក្បាយដោយមេធាវីការពារក្តីឡើយ ។

**សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី *amicus curiae* នៅក្នុងនីតិវិធីអន្តរជាតិ**

4. សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ត្រូវបានគេទទួលយកយ៉ាងទូលំទូលាយនៅតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ និងតុលាការអន្តរជាតិ*មិនអចិន្ត្រៃយ៍* (hybrid courts) ។ ឧទាហរណ៍តុលាការ ICTY នៅក្នុងករណី *Milosevic* តុលាការបានតែងតាំងមេធាវីដើម្បីតួនាទីជាអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដើម្បីធានាថាតុលាការ "ត្រូវបានជូនដំណឹងយ៉ាងពេញលេញអំពីទិដ្ឋភាពនានានៃច្បាប់អន្តរជាតិ"[3] ។ អ្នកធ្វើអត្ថាធិប្បាយបានអង្កេតថាសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីមានសារៈប្រយោជន៍យ៉ាងខ្លាំងនៅតុលាការមិនអចិន្ត្រៃយ៍ (ដូចជាអង្គជំនុំ

---

[1] សូមមើលសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបណ្តឹងសារទុក្ខ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណីកាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារលេខ E188/2 ERN 00589658 (ភាសាអង់គ្លេស) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ។

[2] សូមមើលសេចក្តីជូនដំណឹងរបស់សហមេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188/8, ERN 00595835 (ជាភាសាអង់គ្លេស) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០១០ នៅត្រង់កថាខណ្ឌទី៧(ខ) ។

[3] *Milosevic* (IT-02-54-T) TC, ដីកាសម្រេច ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ និងដីកាសម្រេច ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥

00602078

F7

ជម្រះសាមញ្ញនេះ) ដោយសារតែឥទ្ធិពលទៅវិញទៅមកយ៉ាងស្មុគស្រាញនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ[4] ។

5. អនុលោមតាមអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការពិសេសសេរ៉ាឡេអូន សំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ត្រូវតែបានមើលឃើញក្នុងន័យថាជាជំនួយដ៏សំខាន់ដែលអាចផ្តល់មកឱ្យតុលាការ ហើយសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនេះ ត្រូវតែបានមើលឃើញថាមានសារៈសំខាន់នៅដំណាក់កាលនៃបណ្តឹងសារទុក្ខ[5]។

6. ដោយស្របគ្នានឹងការអនុវត្តនៅកម្រិតអន្តរជាតិ អវតក បានអញ្ជើញដាក់និង/ឬទទួលសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីជាច្រើនដង ។ ក្នុងឱកាសបួនលើកដាច់ដោយឡែកពីគ្នាអង្គបុរេជំនុំជម្រះបានអញ្ជើញអង្គការ និងសាធារណជនឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដើម្បីជួយដល់អង្គបុរេជំនុំជម្រះក្នុងការពិភាក្សាលើបញ្ហានៃការឃុំខ្លួនបណ្តោះអាសន្ន[6]។ អង្គជំនុំជម្រះបានអញ្ជើញសាស្ត្រាចារ្យ Antonio Cassese, Kai Ambos, និង the McGill Centre for Human Rights and Legal Pluralism ឱ្យដាក់សារណា Amicus curiae ទាក់ទងនឹងការអនុវត្ត សហឧក្រិដ្ឋកម្មរួម[7] ហើយអង្គបុរេជំនុំជម្រះបានអញ្ជើញសារណា Amicus curiae ទាក់ទងនឹង ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី[8] ។

## សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងសារទុក្ខបច្ចុប្បន្ន

[4] សូមមើល Sarah Williams និង Hanna Woolaver "តួនាទីរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី Amicus curiae នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ" 6 Int'l Crim L. Rev. 151 2006, នៅត្រង់កថាខណ្ឌទី ១៨៥ ។

[5] *Kallon* (SCSL-2003-07) AC សាលក្រមចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៣ នៅកថាខណ្ឌទី៥-៦ ។

[6] (07-09-001 ECCC), ការជូនដំណឹងរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៧ (02/19-09-2007-ECCC-OCIJ), អបជ០១ ការជូនដំណឹងរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧, អបជ០២ ការជូនដំណឹងរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨, (02/19-09-2007-ECCC-OCIJ), អបជ០៣ ការជូនដំណឹងរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។

[7] (001-18-07-2007-ECCC/OCIJ) អបជ០២ ការអញ្ជើញឱ្យដាក់សារណា Amicus curiae ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧

[8] (02/19-09-2007-ECCC-OCIJ), អបជ០១ ដីកាបង្គាប់ឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន និងការអញ្ជើញដាក់សារណា Amicus curiae ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ។

F7

7. បណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមក្នុងរឿងក្តី ឌុច គឺជាបណ្តឹងសារទុក្ខទី១ដែលត្រូវកាត់សេចក្តីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ។ ដូច្នេះ បញ្ហាថ្មីៗ និងស្មុកស្មាញជាច្រើននៃច្បាប់ព្រហ្មទណ្ឌឧក្រិដ្ឋកម្មអន្តរជាតិ នឹងត្រូវលើកយកមកពិភាក្សា និងសម្រេចជាលើកដំបូង ។ មានន័យថា សាលក្រមស្តាពរក្នុងរឿងក្តី ឌុច នឹងក្លាយជាយុត្តិសាស្ត្រដែលមានឥទ្ធិពលទៅលើការជំនុំជម្រះក្តីក្រោយៗទៀតនៅ អវតក ។ ដូច្នេះ វាចាំបាច់ដែលថាអង្គជំនុំជម្រះតុលាការកំពូលត្រូវតែទទួលបាននូវតុល្យភាពនៃទឡ្ហីករណ៍ ហើយអង្គជំនុំជម្រះតុលាការកំពូលត្រូវតែទទួលបាននូវព័ត៌មានពេញលេញអំពីទិដ្ឋភាពមួយចំនួនទៀតដែលទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

8. ដោយសារតែសហមេធាវីរបស់ ឌុច មានបំណងកម្រិតសារណារបស់ពួកគេត្រឹមបញ្ហាយុត្តាធិការ និងប្រមូលផ្តុំទឡ្ហីករណ៍របស់ពួកគេតែទៅលើច្បាប់ជាតិ នោះសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីដែលបានបង្ហាញពីទិដ្ឋភាពដទៃទៀតនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសារទុក្ខនេះ ឲ្យបានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ។

9. ក្នុងនាមជាអង្គភាពមួយរបស់ អ.វ.ត.ក ដែលជួយធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គភាពគាំពារការការពារក្តី គឺជាអង្គភាពដ៏សាកសមក្នុងការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីក្នុងនៅក្នុងបណ្តឹងសារទុក្ខនេះ[9]”។

## សំណើ

10. អាស្រ័យដូចហេតុផលដែលបានបញ្ជាក់ពីខាងលើ អង្គភាពគាំពារការការពារក្តីស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល ដើម្បីដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្តី ដោយអនុលោមតាមវិធាន៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

សូមអង្គជំនុំជម្រះតុលាការកំពូលទទួលនូវសំណើនេះដោយក្តីគោរព ។

Richard J. Rogers

[9] Kallon, សេចក្តីសម្រេច AC,ខាងលើ,នៅកថាខណ្ឌទី១០។